ក្រសួងមុខងារសាធារណៈ
MINISTRY OF CIVIL SERVICE

# ការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំ ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ឆ្នាំ២០២៣

គុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន ប្រសិទ្ធភាព

https://lms.era.gov.kh/qrlink/2A

ស្កេនទីនេះ ដើម្បីដាក់ពាក្យប្រឡង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

លេខ : ៥៦២៥/២៣ មស.សជណ

# សេចក្តីជូនដំណឹង
# ស្តីពី
# ការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំ
# ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**យោង** ៖ - ចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** នាថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ លើលិខិតរបស់ក្រសួងមុខងារសាធារណៈចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣ អំពីរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំពាក់ព័ន្ធនឹងការជ្រើសរើសមន្ត្រីកសិកម្មឃុំ ចំនួន ២៥០នាក់ ក្នុងឆ្នាំ២០២៣

- សេចក្តីសម្រេចលេខ ...៥៦២៤/២៣ មសសជណ ចុះថ្ងៃទី ៣១... ខែតុលា ឆ្នាំ២០២៣ របស់ក្រសួងមុខងារសាធារណៈ
- យោងតាមការចាំបាច់ និងសំណូមពរការងារ

គណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំ សូមជូនដំណឹងដល់សាធារណជនទាំងអស់ឱ្យបានជ្រាបថា គណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំ សម្រេចបើកឱ្យមានការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំ ចំនួន **២៥០នាក់** សម្រាប់ប្រភេទក្របខណ្ឌ **ក, ខ, គ** ដែលមានជំនាញ/ឯកទេសកសិកម្ម ចាប់ពីវិញ្ញាបនបត្រ បរិញ្ញាបត្ររង បរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល ឱ្យចូលបម្រើការងារនៅតាមឃុំ ស្រុក ខេត្ត ក្នុងក្របខណ្ឌក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ឆ្នាំ២០២៣ ដូចមានក្នុងតារាងឧបសម្ព័ន្ធជូនភ្ជាប់។

## ក. លក្ខខណ្ឌនៃការជ្រើសរើស

១. បេក្ខជនត្រូវមានសញ្ជាតិខ្មែរ

២. បេក្ខជនត្រូវមានអាយុយ៉ាងតិច ១៨ឆ្នាំ

៣. លក្ខខណ្ឌអាយុសម្រាប់បេក្ខជនប្រឡងប្រជែងត្រូវបានកំណត់ដូចខាងក្រោម៖

- បេក្ខជនដែលមានកម្រិតបណ្តុះបណ្តាលថ្នាក់បណ្ឌិត ត្រូវបានលើកលែងលក្ខខណ្ឌអាយុ
- បេក្ខជនដែលមានកម្រិតបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឬសមមូលត្រូវមានអាយុច្រើនបំផុត ៤០ឆ្នាំ
- បេក្ខជនដែលមានកម្រិតបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រឬសមមូល ត្រូវមានអាយុច្រើនបំផុត ៣៥ឆ្នាំ
- បេក្ខជនដែលមានកម្រិតបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររងឬសមមូល ត្រូវមានអាយុច្រើនបំផុត ២៨ឆ្នាំ
- បេក្ខជនដែលមានកម្រិតបណ្តុះបណ្តាលវិញ្ញាបនបត្រឬសមមូល ត្រូវមានអាយុច្រើនបំផុត ២៥ឆ្នាំ
- បេក្ខជនជាមន្ត្រីរាជការត្រូវបានលើកលែងលក្ខខណ្ឌអាយុ

៤. មិនប្រាសចាកសិទ្ធិខាងផ្លូវរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និងសិទ្ធិខាងនយោបាយ

៥. ការលើកទឹកចិត្ត និងការផ្តល់អាទិភាព

- សម្រាប់អ្នកដែលមានសញ្ញាបត្រខ្ពស់ ជំនាញកសិកម្ម
- បទពិសោធន៍ការងារលើវិស័យកសិកម្ម
- ស្ត្រីភេទ
- អ្នកដែលមានទីលំនៅអចិន្ត្រៃយ៍ក្នុងឃុំ ស្រុក ខេត្ត ដែលត្រូវជ្រើសរើសមន្ត្រីកសិកម្មឃុំ។



ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

## ខ. កាលបរិច្ឆេទចុះឈ្មោះប្រឡងប្រជែង និងការដាក់ពាក្យ

១. កាលបរិច្ឆេទចុះឈ្មោះប្រឡងប្រជែងចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៣ រហូតដល់ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ១៧:០០ រសៀលជាកំហិត

២. ការដាក់ពាក្យប្រឡងប្រជែងតាមរយៈ ៖

- ប្រព័ន្ធអនឡាញ ដោយបេក្ខជនអាចស្កេន QR Code ឬ ចូលទៅកាន់គេហទំព័រ http://era.gov.kh/ ដើម្បីបំពេញព័ត៌មាន សុំសិទ្ធិប្រឡងប្រជែង និងស្កេនបញ្ចូលឯកសារច្បាប់ដើម
- បេក្ខជនអាចទំនាក់ទំនងជាមួយមន្ទីរមុខងារសាធារណៈខេត្តពាក់ព័ន្ធដែលជ្រើសរើសមន្ត្រីកសិកម្មឃុំ ដើម្បីបំពេញព័ត៌មានសុំសិទ្ធិប្រឡងប្រជែង និងស្កេនបញ្ចូលឯកសារច្បាប់ដើម

៣. ឯកសារតម្រូវ

- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬ ឆាយា (ព្រះសង្ឃ)
- វិញ្ញាបនបត្រ ឬ សញ្ញាបត្រ ចុងក្រោយ
- រូបថតទំហំ ៤ x ៦ (ផ្ទៃខាងក្រោយពណ៌ស)
- លិខិតបញ្ជាក់រដ្ឋបាលចេញដោយប្រធានអង្គភាពទទួលបន្ទុកបុគ្គលិក ឬ ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ ដែលមានសុពលភាពរយៈពេល ០៣(បី)ខែ សម្រាប់មន្ត្រីរាជការ

៤. នៅពេលប្រឡងជាប់ជាស្ថាពរ បេក្ខជនត្រូវផ្តល់ឯកសារមកនាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធ្វើការផ្ទៀងផ្ទាត់ដូចខាងក្រោម៖

| | |
|---|---|
| - សេចក្តីចម្លងវិញ្ញាបនបត្រ ឬសញ្ញាបត្រ (បញ្ជាក់ផ្លូវការ) | ចំនួន ០១ច្បាប់ |
| - សេចក្តីចម្លងសំបុត្រកំណើត | ចំនួន ០១ច្បាប់ |
| - សេចក្តីចម្លងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ(បញ្ជាក់ផ្លូវការ) | ចំនួន ០១ច្បាប់ |
| - លិខិតអនុញ្ញាតរបស់ប្រធានស្ថាប័ន(សម្រាប់បេក្ខជនជាមន្ត្រីរាជការ) | ចំនួន ០១ច្បាប់ |
| - លិខិតថ្កោលទោស(សម្រាប់បេក្ខជនជានិស្សិត) | ចំនួន ០១ច្បាប់ |
| - លិខិតបញ្ជាក់សុខភាព(សម្រាប់បេក្ខជនជានិស្សិត) | ចំនួន ០១ច្បាប់ |
| - រូបថតចំពីមុខ គ្មានពាក់មួក គ្មានពាក់វ៉ែនតា ទំហំ ៤ x ៦ | ចំនួន ០២សន្លឹក។ |

## គ. លក្ខខណ្ឌវិញ្ញាបនបត្រ ឬសញ្ញាបត្រ

១. ករណីរកឃើញមានការក្លែងបន្លំវិញ្ញាបនបត្រ សញ្ញាបត្រ ឬ លិខិតស្នាមផ្សេងៗ បេក្ខជននឹងត្រូវលុបឈ្មោះចេញជាស្វ័យប្រវត្តិ ទោះបីជាបេក្ខជននោះ បានប្រឡងជាប់ជាស្ថាពរក៏ដោយ និងត្រូវប្រឈមចំពោះមុខច្បាប់ជាធរមាន

២. ចំពោះវិញ្ញាបនបត្រ ឬ សញ្ញាបត្រ ដែលបានបញ្ចប់ការសិក្សាពីបរទេស ត្រូវយកទៅបញ្ជាក់ជាភាសាជាតិ ដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា និងវិញ្ញាបនបត្រ ឬ សញ្ញាបត្រជាភាសាបរទេស (ក្នុងស្រុក) ត្រូវបញ្ជាក់ជាភាសាជាតិពីគ្រឹះស្ថានសិក្សាសាមី។

## ឃ. លក្ខខណ្ឌការងារ

១. បេក្ខជនដែលបានមានបំណងចូលរួមការប្រឡងប្រជែង ត្រូវជ្រើសរើសទីកន្លែងបំពេញការងារជាក់លាក់ (ឃុំ ស្រុក ខេត្ត) ក្នុងតារាងភ្ជាប់ជាមួយ ជាមុន និងមិនត្រូវបានអនុញ្ញាតឱ្យផ្លាស់ប្តូរកន្លែងការងារដោយហេតុផលណាមួយឡើយ។ ការស្នើសុំផ្លាស់ប្តូរកន្លែងការងារ មានន័យថាសាមីជននោះបោះបង់ក្របខណ្ឌមន្ត្រីរាជការ

២. បេក្ខសមណៈ(ជាបព្វជិត ឬ ព្រះសង្ឃ) មានមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សា នៃក្រសួងធម្មការ និងសាសនា នៅពេលប្រឡងជាប់ជាស្ថាពរ គឺតម្រូវឱ្យលាចាកសិក្ខាបទ និងមិនរក្សាបានមុខតំណែងឡើយ

៣. បេក្ខជនជាមន្ត្រីរាជការ ក្រោយពេលប្រឡងជាប់ជាស្ថាពរ ត្រូវបានរក្សាអតីតភាពការងារ ប៉ុន្តែមិនរក្សាមុខតំណែងគ្រប់គ្រងទេ និងត្រូវបានរៀបចំផ្ទេរបៀវត្សទៅកាន់អង្គភាពថ្មី។

**ង. អត្ថប្រយោជន៍ការងារ**

១. បេក្ខជនដែលបានប្រឡងជាប់ជាស្ថាពរនឹងត្រូវធ្វើកម្មសិក្សា និងតាំងស៊ប់ក្នុងប្រភេទក្របខណ្ឌ **ក, ខ, គ** ផ្អែកលើកម្រិតបណ្ដុះបណ្ដាលរបស់សាមីខ្លួន

២. បេក្ខជនដែលបានប្រឡងជាប់ជាស្ថាពរ នឹងត្រូវទទួលបានប្រាក់បៀវត្សទាបបំផុតចាប់ពី **១,៤០០,០០០៛** ទៅតាមប្រភេទក្របខណ្ឌ និងទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែ ចំនួន **១៦០,០០០៛** ក្នុង១ខែ រួមទាំងអត្ថប្រយោជន៍ផ្សេងៗទៀតរបស់មន្ត្រីរាជការស៊ីវិល។

**ច. វិញ្ញាសាប្រឡង**

១. សំណួរ-ចម្លើយ ពាក់ព័ន្ធនឹងវិស័យកសិកម្ម រយៈពេល ២ម៉ោង **៥០ពិន្ទុ (មេគុណ២)**

២. ភាសាអង់គ្លេស រយៈពេល ១ម៉ោង **៥០ពិន្ទុ (មេគុណ១)**

៣. សំណួរពហុចម្លើយពាក់ព័ន្ធនឹងចំណេះដឹងទូទៅផ្នែក គណិតសាស្ត្រ ភូមិសាស្ត្រ រដ្ឋបាលសាធារណៈ មុខងារសាធារណៈ ក្រមសីលធម៌ ព័ត៌មានវិទ្យា និងកសិកម្ម រយៈពេល ១ម៉ោង **១០០ពិន្ទុ (មេគុណ១)**។

**ឆ. សម័យប្រឡង និងមណ្ឌលប្រឡង**

១. សម័យប្រឡង ៖ នៅសប្ដាហ៍ទី២ ខែធ្នូ ឆ្នាំ២០២៣ កាលបរិច្ឆេទជាក់លាក់នឹង**ជូនដំណឹងពេលក្រោយ**

២. មណ្ឌលប្រឡង ៖ **ជូនដំណឹងពេលក្រោយ**។

**<u>បញ្ជាក់ ៖</u>**

១. បេក្ខជនដែលបានចុះឈ្មោះរួចរាល់ ក្រុមការងារនឹងធ្វើការពិនិត្យផ្ទៀងផ្ទាត់ព័ត៌មាន និងផ្ញើសារ sms.era.gov.kh និងអ៊ីម៉ែលទៅសាមីខ្លួន ដើម្បីបំពេញលក្ខខណ្ឌបន្តទៀត

២. ចំពោះព័ត៌មានផ្សេងទៀតបេក្ខជនអាចទាក់ទងតាមទូរស័ព្ទ និងប្រព័ន្ធTelegram ០៧៨ ២៤៣ ២៣៥, ០១២ ៨៤៣ ១១៤ រៀងរាល់ម៉ោងធ្វើការ

៣. គណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំ សូមរក្សាសិទ្ធិកែប្រែក្នុងករណីចាំបាច់។

ថ្ងៃ ចន្ទ ១២ រោច ខែ អស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០២៣

**រដ្ឋមន្ត្រី និងជា**

**ប្រធានគណៈកម្មការរៀបចំការប្រឡង**

**ហ៊ុន_ម៉ានី**

ស្កេន ដើម្បីបំពេញពាក្យសុំសិទ្ធិប្រឡង

https://lms.era.gov.kh/qrlink/2A

**ចម្លងជូន៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  "ដើម្បីសហការអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
គណៈកម្មការរៀបចំការប្រឡងប្រជែង

## តារាងឧបសម្ព័ន្ធបែងចែកអង្គភាពជ្រើសរើសមន្ត្រីកសិកម្មឃុំ ២៥០កន្លែង នៅតាមភូមិសាស្ត្រគោលដៅ

| ល.រ | ខេត្ត | ស្រុក | ឃុំ | ចំនួន |
|---|---|---|---|---|
| ១ | ១. ខេត្តតាកែវ | ស្រុកអង្គរបូរី | បាស្រែ | ១កន្លែង |
| ២ | | | ពន្លៃ | ១កន្លែង |
| ៣ | | ស្រុកបាទី | ពត់សរ | ១កន្លែង |
| ៤ | | | ចំប៉ី | ១កន្លែង |
| ៥ | | ស្រុកបូរីជលសារ | គោកពោធិ៍ | ១កន្លែង |
| ៦ | | | ជ័យជោគ | ១កន្លែង |
| ៧ | | ស្រុកគិរីវង់ | តាអូរ | ១កន្លែង |
| ៨ | | | ព្រៃរំដេង | ១កន្លែង |
| ៩ | | ស្រុកកោះអណ្ដែត | ក្រពុំឈូក | ១កន្លែង |
| ១០ | | | ព្រៃខ្លា | ១កន្លែង |
| ១១ | | ស្រុកព្រៃកប្បាស | ចារ | ១កន្លែង |
| ១២ | | | កំពែង | ១កន្លែង |
| ១៣ | | ស្រុកសំរោង | សឹង្ហ | ១កន្លែង |
| ១៤ | | | ទ្រា | ១កន្លែង |
| ១៥ | | ស្រុកត្រាំកក់ | អូរសារាយ | ១កន្លែង |
| ១៦ | | | ត្រពាំងក្រញូង | ១កន្លែង |
| ១៧ | | | ត្រពាំងធំខាងត្បូង | ១កន្លែង |
| ១៨ | | | ជាងទង | ១កន្លែង |
| ១៩ | | ស្រុកទ្រាំង | ធ្លក | ១កន្លែង |
| ២០ | | | សំបួរ | ១កន្លែង |
| ២១ | ២. ខេត្តកំពង់ស្ពឺ | ស្រុកភ្នំស្រួច | តាំងសំរោង | ១កន្លែង |
| ២២ | | | មហាសាំង | ១កន្លែង |
| ២៣ | | | ព្រៃក្មេង | ១កន្លែង |
| ២៤ | | | ជាំសង្កែ | ១កន្លែង |
| ២៥ | | ស្រុកសំរោងទង | វល្លិសរ | ១កន្លែង |
| ២៦ | | | តាំងក្រូច | ១កន្លែង |
| ២៧ | | | សំរោងទង | ១កន្លែង |
| ២៨ | | ស្រុកបសេដ្ឋ | កាត់ភ្លុក | ១កន្លែង |
| ២៩ | | | ស្វាយចចិប | ១កន្លែង |
| ៣០ | | | ព្រះខែ | ១កន្លែង |
| ៣១ | | | ពោធិ៍អង្ក្រង | ១កន្លែង |
| ៣២ | | ស្រុកថ្ពង | រុងរឿង | ១កន្លែង |
| ៣៣ | | | ប្រាំបីមុម | ១កន្លែង |

| ល.រ | ខេត្ត | ស្រុក | ឃុំ | ចំនួន |
|---|---|---|---|---|
| ៣៤ | ៣. ខេត្តកំពង់ធំ | ស្រុកបារាយណ៍ | បារាយណ៍ | ១កន្លែង |
| ៣៥ | | | ត្នោតជុំ | ១កន្លែង |
| ៣៦ | | ស្រុកកំពង់ស្វាយ | កំពង់គោ | ១កន្លែង |
| ៣៧ | | | សាន់គរ | ១កន្លែង |
| ៣៨ | | ក្រុងស្ទឹងសែន | អូរគន្ធរ | ១កន្លែង |
| ៣៩ | | | ស្រយ៉ូវ | ១កន្លែង |
| ៤០ | | ស្រុកប្រាសាទសំបូរ | សំបូរ | ១កន្លែង |
| ៤១ | | | តាំងក្រសៅ | ១កន្លែង |
| ៤២ | | ស្រុកសណ្ដាន់ | មានជ័យ | ១កន្លែង |
| ៤៣ | | | ងន | ១កន្លែង |
| ៤៤ | | ស្រុកសន្ទុក | កកោះ | ១កន្លែង |
| ៤៥ | | | តាំងក្រសាំង | ១កន្លែង |
| ៤៦ | | ស្រុកស្ទោង | ចំណារក្រោម | ១កន្លែង |
| ៤៧ | | | ប្រឡាយ | ១កន្លែង |
| ៤៨ | | | សំព្រោជ | ១កន្លែង |
| ៤៩ | | | បន្ទាយស្ទោង | ១កន្លែង |
| ៥០ | | ស្រុកតាំងគោក | ពង្រ | ១កន្លែង |
| ៥១ | | | ទ្រៀល | ១កន្លែង |
| ៥២ | ៤. ខេត្តសៀមរាប | ស្រុកជីក្រែង | អន្លង់សំណរ | ១កន្លែង |
| ៥៣ | | | ស្ពានត្នោត | ១កន្លែង |
| ៥៤ | | ស្រុកក្រឡាញ់ | សំបួរ | ១កន្លែង |
| ៥៥ | | | ស្រណាល | ១កន្លែង |
| ៥៦ | | ស្រុកពួក | ព្រៃជ្រូក | ១កន្លែង |
| ៥៧ | | | សំរោងយា | ១កន្លែង |
| ៥៨ | | ស្រុកប្រាសាទបាគង | កណ្ដែក | ១កន្លែង |
| ៥៩ | | | ត្រពាំងធំ | ១កន្លែង |
| ៦០ | | ស្រុកសូទ្រនិគម | កៀនសង្កែ | ១កន្លែង |
| ៦១ | | | ដានរុន | ១កន្លែង |
| ៦២ | ៥. ខេត្តបន្ទាយមានជ័យ | ស្រុកមង្គលបូរី | បន្ទាយនាង | ១កន្លែង |
| ៦៣ | | | ចំណោម | ១កន្លែង |
| ៦៤ | | | រហាត់ទឹក | ១កន្លែង |
| ៦៥ | | | សំបួរ | ១កន្លែង |
| ៦៦ | | | សឿ | ១កន្លែង |
| ៦៧ | | | ស្រះរាំង | ១កន្លែង |
| ៦៨ | | ស្រុកភ្នំស្រុក | ណាំតៅ | ១កន្លែង |
| ៦៩ | | | ប៉ោយចារ | ១កន្លែង |
| ៧០ | | | ពន្លៃ | ១កន្លែង |
| ៧១ | | | ស្រះជីក | ១កន្លែង |

| ល.រ | ខេត្ត | ស្រុក | ឃុំ | ចំនួន |
|---|---|---|---|---|
| ៧២ | | ព្រះនេត្រព្រះ | ភ្នំលៀប | ១កន្លែង |
| ៧៣ | | | ប្រាសាទ | ១កន្លែង |
| ៧៤ | | | ព្រះនេត្រព្រះ | ១កន្លែង |
| ៧៥ | | | រហាល | ១កន្លែង |
| ៧៦ | | | ទានកាំ | ១កន្លែង |
| ៧៧ | | | ទឹកជោរ | ១កន្លែង |
| ៧៨ | | ស្រុកអូរជ្រៅ | គុត្តសត | ១កន្លែង |
| ៧៩ | | | សំរោង | ១កន្លែង |
| ៨០ | | ស្រុកថ្មពួក | បន្ទាយឆ្មារ | ១កន្លែង |
| ៨១ | | | គោករមៀត | ១កន្លែង |
| ៨២ | | | ថ្មពួក | ១កន្លែង |
| ៨៣ | | | គោកកប៉ិន | ១កន្លែង |
| ៨៤ | | ស្រុកស្វាយចេក | ស្វាយចេក | ១កន្លែង |
| ៨៥ | | | តាផូ | ១កន្លែង |
| ៨៦ | | | ផ្គាំ | ១កន្លែង |
| ៨៧ | | | ទ្រាស | ១កន្លែង |
| ៨៨ | ៦. ខេត្តកំពង់ចាម | ស្រុកបាធាយ | បាធាយ | ១កន្លែង |
| ៨៩ | | | ជាលា | ១កន្លែង |
| ៩០ | | | សំបូរ | ១កន្លែង |
| ៩១ | | | តាំងក្រសាំង | ១កន្លែង |
| ៩២ | | | ត្រប់ | ១កន្លែង |
| ៩៣ | | ស្រុកព្រៃឈរ | មៀន | ១កន្លែង |
| ៩៤ | | | ល្វា | ១កន្លែង |
| ៩៥ | | | ស្រងែ | ១កន្លែង |
| ៩៦ | | | គុងរុង | ១កន្លែង |
| ៩៧ | | ស្រុកស្រីសន្ធរ | បារាយណ៍ | ១កន្លែង |
| ៩៨ | | | ប្រាំយាម | ១កន្លែង |
| ៩៩ | | | ព្រែករំដេង | ១កន្លែង |
| ១០០ | | ស្រុកជើងព្រៃ | ខ្វរដំបង | ១កន្លែង |
| ១០១ | | | គោករវៀង | ១កន្លែង |
| ១០២ | | | ផ្តៅជុំ | ១កន្លែង |
| ១០៣ | | | ព្រៃចារ | ១កន្លែង |
| ១០៤ | | | ព្រីងជ្រុំ | ១កន្លែង |
| ១០៥ | | | សំពងជ័យ | ១កន្លែង |
| ១០៦ | | | ស្តើងជ័យ | ១កន្លែង |
| ១០៧ | | | សូទិព្វ | ១កន្លែង |
| ១០៨ | | | ស្រម៉រ | ១កន្លែង |
| ១០៩ | | | ត្រពាំងគរ | ១កន្លែង |

| ល.រ | ខេត្ត | ស្រុក | ឃុំ | ចំនួន |
|---|---|---|---|---|
| ១១០ | ៧. ខេត្តកំពង់ឆ្នាំង | ស្រុកបរិបូណ៌ | មេលំ | ១កន្លែង |
| ១១១ | | | ខុនរ៉ង | ១កន្លែង |
| ១១២ | | ស្រុកជលគីរី | កោះថ្កូវ | ១កន្លែង |
| ១១៣ | | | ព្រៃគ្រី | ១កន្លែង |
| ១១៤ | | ស្រុកកំពង់ត្រឡាច | អំពិលទឹក | ១កន្លែង |
| ១១៥ | | | តាជេស | ១កន្លែង |
| ១១៦ | | ស្រុករលាប្អៀរ | ជ្រៃបាក់ | ១កន្លែង |
| ១១៧ | | | គោកបន្ទាយ | ១កន្លែង |
| ១១៨ | | | ស្វាយជ្រុំ | ១កន្លែង |
| ១១៩ | | | ទឹកហូត | ១កន្លែង |
| ១២០ | | ស្រុកសាមគ្គីមានជ័យ | ក្រាំងល្វា | ១កន្លែង |
| ១២១ | | | ត្បែងខ្ពស់ | ១កន្លែង |
| ១២២ | | | ស្វាយជុក | ១កន្លែង |
| ១២៣ | | | ស្វាយ | ១កន្លែង |
| ១២៤ | | ស្រុកទឹកផុស | ខ្លុងពពក | ១កន្លែង |
| ១២៥ | | | ជៀប | ១កន្លែង |
| ១២៦ | | | អភិវឌ្ឍន៍ | ១កន្លែង |
| ១២៧ | | | តាំងក្រសាំង | ១កន្លែង |
| ១២៨ | ៨. ខេត្តបាត់ដំបង | ស្រុកបាណន់ | កន្ទឺ ១ | ១កន្លែង |
| ១២៩ | | | ចែងមានជ័យ | ១កន្លែង |
| ១៣០ | | | តាក្រាម | ១កន្លែង |
| ១៣១ | | ស្រុកថ្មគោល | ជ្រោយស្ដៅ | ១កន្លែង |
| ១៣២ | | | បឹងព្រីង | ១កន្លែង |
| ១៣៣ | | | អូរតាគី | ១កន្លែង |
| ១៣៤ | | | អន្លង់រុន | ១កន្លែង |
| ១៣៥ | | ស្រុកបវេល | ល្វា | ១កន្លែង |
| ១៣៦ | | | អំពិលប្រាំដើម | ១កន្លែង |
| ១៣៧ | | | ឃ្លាំងមាស | ១កន្លែង |
| ១៣៨ | | ស្រុកមោងឫស្សី | ព្រៃស្វាយ | ១កន្លែង |
| ១៣៩ | | | ឫស្សីក្រាំង | ១កន្លែង |
| ១៤០ | | | ជ្រៃ | ១កន្លែង |
| ១៤១ | | | ព្រៃតូច | ១កន្លែង |
| ១៤២ | | ស្រុកសង្កែ | តាប៉ុន | ១កន្លែង |
| ១៤៣ | | | កំពង់ព្រៀង | ១កន្លែង |
| ១៤៤ | | | រាំងកេសី | ១កន្លែង |
| ១៤៥ | | ស្រុកគាស់ក្រឡ | ធិបតី | ១កន្លែង |
| ១៤៦ | | | ព្រះផុស | ១កន្លែង |
| ១៤៧ | | | ឆ្នាលមាន់ | ១កន្លែង |

| ល.រ | ខេត្ត | ស្រុក | ឃុំ | ចំនួន |
|---|---|---|---|---|
| ១៤៨ | | ស្រុករុក្ខគិរី | មុខរាហ៍ | ១កន្លែង |
| ១៤៩ | | | ស្អកប្រវែក | ១កន្លែង |
| ១៥០ | ៩.ខេត្តកំពត | ស្រុកបន្ទាយមាស | ព្រៃទន្លេ | ១កន្លែង |
| ១៥១ | | | ត្នោតចុងស្រង់ | ១កន្លែង |
| ១៥២ | | ស្រុកកំពង់ត្រាច | ព្រែកក្រឹស | ១កន្លែង |
| ១៥៣ | | | បឹងសាលាខាងជើង | ១កន្លែង |
| ១៥៤ | | ស្រុកទឹកឈូ | កណ្តាល | ១កន្លែង |
| ១៥៥ | | | កូនសត្វ | ១កន្លែង |
| ១៥៦ | | ស្រុកជុំគីរី | ច្រេស | ១កន្លែង |
| ១៥៧ | | | ស្រែចែង | ១កន្លែង |
| ១៥៨ | | | ជំពូវន្ត | ១កន្លែង |
| ១៥៩ | | ស្រុកដងទង់ | ដំណាក់សុក្រំ | ១កន្លែង |
| ១៦០ | | | អង្គរមាស | ១កន្លែង |
| ១៦១ | | | ល្អាង | ១កន្លែង |
| ១៦២ | | ស្រុកឈូក | បានៀវ | ១កន្លែង |
| ១៦៣ | | | ល្បើក | ១កន្លែង |
| ១៦៤ | ១០. ខេត្តពោធិ៍សាត់ | ស្រុកបាកាន | បឹងបត់កណ្តាល | ១កន្លែង |
| ១៦៥ | | | មេទឹក | ១កន្លែង |
| ១៦៦ | | | អូរតាប៉ោង | ១កន្លែង |
| ១៦៧ | | | រំលេច | ១កន្លែង |
| ១៦៨ | | | ត្រពាំងជង | ១កន្លែង |
| ១៦៩ | | ស្រុកកណ្តៀង | ស្យា | ១កន្លែង |
| ១៧០ | | | កញ្ចរ | ១កន្លែង |
| ១៧១ | | | ស្រែស្តុក | ១កន្លែង |
| ១៧២ | | | កោះជុំ | ១កន្លែង |
| ១៧៣ | | | ស្វាយលួង | ១កន្លែង |
| ១៧៤ | | ស្រុកក្រគរ | ឈើតុំ | ១កន្លែង |
| ១៧៥ | | | ត្នោតជុំ | ១កន្លែង |
| ១៧៦ | | | ស្វាយស | ១កន្លែង |
| ១៧៧ | | | ក្បាលត្រាច | ១កន្លែង |
| ១៧៨ | | | អូរសណ្តាន់ | ១កន្លែង |
| ១៧៩ | | ស្រុកតាលោសែនជ័យ | តាលោ | ១កន្លែង |
| ១៨០ | | | ផ្ទះរុង | ១កន្លែង |
| ១៨១ | ១១. ខេត្តព្រៃវែង | ស្រុកបាភ្នំ | ឈើកាច់ | ១កន្លែង |
| ១៨២ | | | ជាយ | ១កន្លែង |
| ១៨៣ | | ស្រុកកំចាយមារ | ស៊ាងឃ្វាង | ១កន្លែង |
| ១៨៤ | | | ស្មោងជើង | ១កន្លែង |
| ១៨៥ | | ស្រុកកំពង់ត្របែក | ចាម | ១កន្លែង |
| ១៨៦ | | | ពាមមន្ទា | ១កន្លែង |

| ល.រ | ខេត្ត | ស្រុក | ឃុំ | ចំនួន |
|---|---|---|---|---|
| ១៨៧ | | ស្រុកកញ្ជៀច | ក្អៀងរាយ | ១កន្លែង |
| ១៨៨ | | | ព្រាល | ១កន្លែង |
| ១៨៩ | | ស្រុកមេសាង | ជីផុច | ១កន្លែង |
| ១៩០ | | | ព្រៃឃ្នេស | ១កន្លែង |
| ១៩១ | | ស្រុកពារាំង | កញ្ចំ | ១កន្លែង |
| ១៩២ | | | ព្រៃញ្ញៅ | ១កន្លែង |
| ១៩៣ | | ស្រុកព្រះស្ដេច | បន្ទាយចក្រី | ១កន្លែង |
| ១៩៤ | | | ព្រះស្ដេច | ១កន្លែង |
| ១៩៥ | | ស្រុកស៊ីធរកណ្ដាល | ជ្រៃឃ្មុំ | ១កន្លែង |
| ១៩៦ | | | ឫស្សីសាញ់ | ១កន្លែង |
| ១៩៧ | | ស្រុកស្វាយអន្ទរ | ពានរោង | ១កន្លែង |
| ១៩៨ | | | សំរោង | ១កន្លែង |
| ១៩៩ | ១២. ខេត្តព្រះវិហារ | ស្រុកជ័យសែន | ស្អាង | ១កន្លែង |
| ២០០ | | | ពុទ្រា | ១កន្លែង |
| ២០១ | | | ខ្យង | ១កន្លែង |
| ២០២ | | ស្រុកឆែប | ម្លូព្រៃមួយ | ១កន្លែង |
| ២០៣ | | | ម្លូព្រៃពីរ | ១កន្លែង |
| ២០៤ | | | ឆែបមួយ | ១កន្លែង |
| ២០៥ | | ស្រុកជាំក្សាន្ត | ជាំក្សាន្ត | ១កន្លែង |
| ២០៦ | | | ទឹកក្រហម | ១កន្លែង |
| ២០៧ | | | កងពល | ១កន្លែង |
| ២០៨ | | ស្រុកគូលែន | ស្រយង់ | ១កន្លែង |
| ២០៩ | | | គូលែនត្បូង | ១កន្លែង |
| ២១០ | | | ភ្នំត្បែងពីរ | ១កន្លែង |
| ២១១ | | ស្រុករវៀង | រៀបរយ | ១កន្លែង |
| ២១២ | | | រក្សា | ១កន្លែង |
| ២១៣ | | | រំដោះ | ១កន្លែង |
| ២១៤ | | ស្រុកសង្គមថ្មី | ចំរើន | ១កន្លែង |
| ២១៥ | | | រណសិរ្ស | ១កន្លែង |
| ២១៦ | | | រអាង | ១កន្លែង |
| ២១៧ | | ស្រុកត្បែងមានជ័យ | ឈានមុខ | ១កន្លែង |
| ២១៨ | | | ពោធិ៍ | ១កន្លែង |
| ២១៩ | | | ប្រមេរ | ១កន្លែង |
| ២២០ | ១៣. ខេត្តត្បូងឃ្មុំ | ស្រុកតំបែរ | ត្រពាំងព្រីង | ១កន្លែង |
| ២២១ | | | គោកស្រុក | ១កន្លែង |
| ២២២ | | | តំបែរ | ១កន្លែង |
| ២២៣ | | ស្រុកអូររាំងឪ | អំពិលតាពក | ១កន្លែង |
| ២២៤ | | | មៀន | ១កន្លែង |

| ល.រ | ខេត្ត | ស្រុក | ឃុំ | ចំនួន |
|---|---|---|---|---|
| ២២៥ | | ស្រុកពញាក្រែក | ដូនតី | ១កន្លែង |
| ២២៦ | | | កក់ | ១កន្លែង |
| ២២៧ | | | កណ្ដោលជ្រុំ | ១កន្លែង |
| ២២៨ | ១៤. ខេត្តស្វាយរៀង | ស្រុករមាសហែក | ជ្រុង | ១កន្លែង |
| ២២៩ | | | ត្រពាំងស្ដៅ | ១កន្លែង |
| ២៣០ | | ស្រុកស្វាយជ្រុំ | គ្រួស | ១កន្លែង |
| ២៣១ | | | ស្វាយធំ | ១កន្លែង |
| ២៣២ | | ស្រុកស្វាយទាប | ប្រសូត្រ | ១កន្លែង |
| ២៣៣ | | | គគីសោម | ១កន្លែង |
| ២៣៤ | | ក្រុងបាវិត | ប្រចាំម្ទេស | ១កន្លែង |
| ២៣៥ | ១៥. ខេត្តឧត្ដរមានជ័យ | ស្រុកអន្លង់វែង | លំទង | ១កន្លែង |
| ២៣៦ | | | អន្លង់វែង | ១កន្លែង |
| ២៣៧ | | ស្រុកបន្ទាយអំពិល | គោកមន | ១កន្លែង |
| ២៣៨ | | | អំពិល | ១កន្លែង |
| ២៣៩ | | ស្រុកចុងកាល់ | ចុងកាល់ | ១កន្លែង |
| ២៤០ | | | ពង្រ | ១កន្លែង |
| ២៤១ | | | ក្រសាំង | ១កន្លែង |
| ២៤២ | | | ជើងទៀន | ១កន្លែង |
| ២៤៣ | ១៦. ខេត្តកណ្ដាល | ស្រុកស្អាង | ព្រែកអំបិល | ១កន្លែង |
| ២៤៤ | | | ក្រាំងយ៉ូវ | ១កន្លែង |
| ២៤៥ | | ស្រុកខ្សាច់កណ្ដាល | ដើធំ | ១កន្លែង |
| ២៤៦ | | | កោះរះជន្លឹង | ១កន្លែង |
| ២៤៧ | | ស្រុកពញាឮ | ភ្នំបាទ | ១កន្លែង |
| ២៤៨ | | | កំពង់អុស | ១កន្លែង |
| ២៤៩ | ១៧. ខេត្តមណ្ឌលគិរី | ស្រុកកោះញែក | ស្រែសង្គម | ១កន្លែង |
| ២៥០ | | | ស្រែហ៊ុយ | ១កន្លែង |

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០២៣

**រដ្ឋមន្ត្រី និងជា**

**ប្រធានគណៈកម្មការរៀបចំការប្រឡងប្រជែង**

**ហ៊ុន_ម៉ានី**